**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## នាឱកាសពិធីបុណ្យទន្លេលើកទី៤ ថ្ងៃទី០៩-១១ ខែមីនា ឆ្នាំ២០១៨ នៅខេត្តកណ្តាល
## ក្រោមប្រធានបទៈ "ទន្លេនៃសន្តិភាព មិត្តភាព និងនិរន្តរភាពទេសចរណ៍"

- *ជនរួមជាតិទាំងអស់ជាទីមេត្រី !*

ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវការវិវឌ្ឍយ៉ាងច្រើនទាំងក្នុងទិដ្ឋភាពនយោបាយ សន្តិសុខ សេដ្ឋកិច្ច និងសង្គម។ តាមរយៈនយោបាយ **ឈ្នះ ឈ្នះ** កម្ពុជាបានផ្លាស់ប្តូររូបភាពយ៉ាងឆាប់រហ័សពីអ្វីដែលធ្លាប់ស្គាល់ថា ជាទឹកដីនៃវាលពិឃាត ទឹកដីសង្គ្រាម សំបូរដោយគ្រាប់មីន មកជាកម្ពុជាមួយដែលមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាពពេញលេញ និងមានការអភិវឌ្ឍរីកចំរើនលើគ្រប់វិស័យប្រកបដោយក្តីសង្ឃឹមឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង និងត្រចះត្រចង់។

ក្នុងស្មារតីឆ្លើយតបទៅនឹងនិន្នាការនៃការអភិវឌ្ឍនេះ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាព ដើរតួនាទីជា "**មាសបៃតង**" រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈការបង្កើតនិងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ទ្រទ្រង់កំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ពិសេសចូលរួមដល់ការឆ្លើយតបនឹងបំរែបំរួលអាកាសធាតុ ដែលជាបញ្ហាប្រឈមជាសាកល។

ជាមួយគ្នានេះ វិស័យទេសចរណ៍បាននិងកំពុងលើកកម្ពស់កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាលើឆាកអន្តរជាតិផងដែរ។ ជាក់ស្តែងក្នុងឆ្នាំ២០១៧នេះ ក្រុមប្រឹក្សាពាណិជ្ជកម្ម និងទេសចរណ៍អឺរ៉ុបបានបោះឆ្នោតជ្រើសរើស "រាជធានីភ្នំពេញជារាជធានីវប្បធម៌ និងទេសចរណ៍ពិភពលោក" ហើយ "ប្រាសាទអង្គរវត្តរបស់កម្ពុជាបន្តជាប់ចំណាត់ថ្នាក់លេខ១ ជាសំណង់ប្រវត្តិសាស្ត្រដ៏ល្អបំផុតលើពិភពលោកសម្រាប់ឆ្នាំ២០១៧" ដែលនេះពិតជាបានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សពីសភាពការណ៍ពិតរបស់កម្ពុជានាពេលបច្ចុប្បន្ន និងអរិយភាពរបស់កម្ពុជាជាគោលដៅទេសចរណ៍ "**វប្បធម៌ និងធម្មជាតិ**" ហើយកម្ពុជាបាននិងកំពុងក្លាយជាបេះដូង និងគោលដៅទេសចរណ៍ដ៏ទាក់ទាញនៃតំបន់អាស៊ីអាគ្នេយ៍។

ទន្ទឹមនឹងនេះ ភាពសម្បូរបែបនៃសក្តានុពលទេសចរណ៍តាមដងទន្លេ បាននិងកំពុងរួមចំណែកធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយឧត្តមភាព និងភាពទាក់ទាញខ្ពស់ និងចូលរួមចំណែកសម្រេចចក្ខុវិស័យអាស៊ានជាគោលដៅទេសចរណ៍លំដាប់ថ្នាក់ពិភពលោក និងប្រកបដោយភាពកក់ក្តៅ "ASEAN: the World-Class Destination" និង "ASEAN: Feels the Warmth" ស្របពេលដែលទេសចរណ៍តាមដងទន្លេ ជាពិសេសទេសចរណ៍មេគង្គ បានក្លាយជាផលិតផលទេសចរណ៍សំខាន់មួយសម្រាប់កម្ពុជា ក៏ដូចជាតំបន់អាស៊ាន។

ទឹកទន្លេ ជាប្រភពនៃការចិញ្ចឹមបីបាច់ជីវិត ជាទីកន្លែងដែលបណ្តុះបណ្តាល និងពូនជ្រំនូវអរិយធម៌។ តាំងពីបុរាណកាលមក មនុស្សជាតិរស់នៅតាមបណ្តោយទន្លេ បន្តពូជពង្ស និងរស់នៅដោយបណ្តុំគ្នាពីមួយជំនាន់ទៅមួយជំនាន់។ ទន្លេជាអំណោយពីធម្មជាតិ ដែលជាទីបង្អែកសម្រាប់ការរស់នៅរបស់យើង ហើយកាន់តែជាចំណងធម្មជាតិនៃការជួយយកអាសាគ្នារបស់យើងទៀតផង។ វាបានផ្សារភ្ជាប់ប្រទេសនានា ដែលហូបទឹកនៃទន្លេតែមួយឲ្យក្លាយជាសហគមន៍រួមរស់វាសនាតែមួយ ដែលប្រកបដោយសមភាព ជួយយកអាសាគ្នាដោយស្មោះត្រង់ និងស្និទ្ធស្នាលដូចជាមនុស្សក្នុងគ្រួសារតែមួយ។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានកំណត់ប្រារព្ធពិធីបុណ្យទន្លេ ដែលនឹងក្លាយជាព្រឹត្តិការណ៍ទេសចរណ៍ថ្មីមួយទៀតសម្រាប់កម្ពុជា ដែលមិនត្រឹមតែចូលរួមចំណែកក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍នៃខេត្តជាប់ដងទន្លេរបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមគាំទ្រនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការយកចិត្តទុកដាក់អភិវឌ្ឍតំបន់តាមដងទន្លេប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ជាពិសេសការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការការពារ និងអភិរក្សធនធានធម្មជាតិ ដោយឈរលើការប្តេជ្ញាចិត្តរួមមួយច្បាស់លាស់ក្នុងការរក្សាតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច សង្គមបរិស្ថាន និងវប្បធម៌ប្រជាពលរដ្ឋមូលដ្ឋាន ដូចដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈប្រធានបទនៃពិធីបុណ្យទន្លេលើកទី៤នេះគឺ "ទន្លេនៃសន្តិភាព មិត្តភាព និងនិរន្តរភាព ទេសចរណ៍"។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍នេះក៏ជាឱកាសមួយដើម្បីពង្រឹងគុណភាពសេវាកម្ម និងការបង្កើត និងអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗប្រកបដោយការច្នៃប្រឌិតខ្ពស់ ជាពិសេសទេសចរណ៍តាមនាវា (River-Cruise) សហគមន៍ទេសចរណ៍តាមដងទន្លេ ព្រមទាំងរួមចំណែកជំរុញការតភ្ជាប់រឹតចំណងមិត្តភាពសាមគ្គីភាពរវាងបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដោយបានពង្រឹងភាពជាដៃគូក្នុងក្របខណ្ឌមហាអនុតំបន់មេគង្គ (GMS) មេគង្គ-ជប៉ុន មេគង្គ-គង្គា និងមេគង្គ-ឡានឆាង ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលដោយទទួលបានលទ្ធផលគួរជាទីមោទនៈកាលពីដើមឆ្នាំ ២០១៨នេះ។

ក្រោមម្លប់នៃសន្តិភាព ប្រជាជនយើងកំពុងតែមានជីវភាពកាន់តែល្អប្រសើរ ហើយបានធ្វើអោយពួកគាត់ទទួលបាននូវភាពរីករាយផងដែរ។ ក្នុងន័យនេះរាជរដ្ឋាភិបាលនឹងប្រារព្ធពិធីបុណ្យទន្លេនេះជារៀងរាល់ឆ្នាំនៅតាមបណ្តាខេត្តជាប់ដងទន្លេនៃព្រះរាជាណាចក្រកម្ពុជា ដែលទាំងអស់នេះសបញ្ជាក់ឲ្យឃើញថារាជរដ្ឋាភិបាលបាននិងកំពុងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ពិសេសការអភិវឌ្ឍផលិតផលទេសចរណ៍តាមដងទន្លេ រួមចំណែកធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាពទាំងក្នុងតំបន់ និងឆាកអន្តរជាតិ។

ឆ្លៀតក្នុងឱកាសពិធីដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បងប្អូនជនរួមជាតិទាំងអស់ វិស័យឯកជន សហគ្រាសធុនតូច និងមធ្យម ចូលរួមឲ្យបានផុសផុលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើឲ្យពិធីបុណ្យទន្លេលើកទី៤ឆ្នាំនេះ និងពិធីបុណ្យទន្លេជាបន្តបន្ទាប់ប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ។ លើសពីនេះទៀត ខ្ញុំក៏សូមអំពាវនាវដល់ប្រតិបត្តិករទេសចរណ៍ ទេសចរជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងបងប្អូនប្រជាពលរដ្ឋចូលរួមសកម្មភាពចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" និងសហការថែរក្សាសោភ័ណភាព ភាពស្អាត អនាម័យ បរិស្ថានល្អ ដែលជាកត្តាចម្បងមិនអាចខ្វះបានក្នុងការថែរក្សាសោភ័ណភាពខេត្ត-ក្រុងតាមដងទន្លេឲ្យស្រស់ស្អាតគង់វង្សយូរអង្វែងដើម្បីបន្តទុកជាមរតកដល់កូនចៅជំនាន់ក្រោយ។

ក្នុងន័យទាំងអស់នេះ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ការប្រារព្ធពិធីបុណ្យទន្លេនឹងក្លាយជាកាលានុវត្តភាពដ៏ប្រសើរថ្មីមួយទៀតក្នុងការធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ដែលជាកត្តាចូលរួមចំណែកក្នុងការផ្ដល់ចំណូល ការបង្កើនការងារ និងការចូលរួមកាត់បន្ថយភាពក្រីក្រជូនដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ពិសេសចូលរួមចំណែកធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ និងរបស់កម្ពុជា ព្រមទាំងបង្កើនស្មារតីស្រឡាញ់ជាតិមាតុភូមិ សាមគ្គីភាព និងមិត្តភាពផងដែរ។ ចំពោះមុខនេះ ខ្ញុំក៏សូមជូនពរឲ្យការប្រារព្ធពិធីបុណ្យទន្លេ នាឆ្នាំ២០១៨នេះ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងប្រកបដោយភាពសប្បាយរីករាយ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៨

ហ៊ុន សែន